💡 *Tips of the Week*



(Sin in Islam, Part IV)

(Sin in Islam, Part IV)

غَافِرِ الذَّنبِ وَقَابِلِ التَّوْبِ شَدِيدِ الْعِقَابِ ذِي الطَّوْلِ ۖ لَا إِلَٰهَ إِلَّا هُوَ ۖ إِلَيْهِ الْمَصِيرُ
سورة غافر:3

ទ្រង់ជាអ្នកអភ័យទោសនូវរាល់បាបកម្មទាំងឡាយនិងជា អ្នកទទួលការសារភាពកំហុស ជាអ្នកដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរ និងជា អ្នកដែលមានការប្រោសប្រទានបំផុត។ គ្មានម្ចាស់ណាផ្សេងដែល ត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ចំពោះទ្រង់តែ មួយគត់ជាកន្លែងវិលត្រឡប់។

وَإِذْ قُلْنَا ادْخُلُوا هَٰذِهِ الْقَرْيَةَ فَكُلُوا مِنْهَا حَيْثُ شِئْتُمْ رَغَدًا وَادْخُلُوا الْبَابَ سُجَّدًا وَقُولُوا حِطَّةٌ نَّغْفِرْ لَكُمْ خَطَايَاكُمْ ۚ وَسَنَزِيدُ الْمُحْسِنِينَ
سورة البقرة:58

ហើយ(ចូរចងចាំ)នៅពេលដែលយើងបានមានបន្ទូលថា:ចូរពួកអ្នកចូលទីក្រុងនេះ(ក្រុងយេរ៉ូសាឡឹម) ហើយចូរពួកអ្នក បរិភោគនូវអ្វីៗដែលមាននៅទីនេះដោយរីករាយតាមតែពួកអ្នកត្រូវការ ហើយពួកអ្នកត្រូវចូលតាមទ្វារដោយឱនលំទោននិងប្រើពាក្យសុំទោសយើងនឹងអភ័យទោសឱ្យពួកអ្នកនូវរាល់បាបកម្ម របស់ពួកអ្នក ហើយយើងនឹងបន្ថែម(ផលបុណ្យ)ដល់បណ្តាអ្នក ដែលសាងអំពើល្អ។

قال اللَّه تعالى :﴿ قل يا عبادي الذين أسرفوا على أنفسهم لا تقنطوا من رحمة اللَّه إن اللَّه يغفر الذنوب جميعاً، إنه هو الغفور الرحيم ﴾ .سورة الزمر(53)

អល់ឡោះបានមានបន្ទូលថា ៖ ឱបណ្តាខ្ញុំរបស់យើងដែលបានបំពានលើខ្លួនឯង (តាមរយៈការសាងទង្វើបាបកម្ម) ចូរពួកអ្នកកុំអស់សង្ឃឹមពីក្តីករុណារបស់ អល់ឡោះ។អល់ឡោះពិតជាអភ័យទោសទាំងអស់(ចំពោះអ្នកសារភាពកំហុស)។ ពិតណាស់ ទ្រង់គឺជាអ្នកអភ័យទោស និងអាណិតអាសូរបំផុត។ (អាល់ហ្សុមើរ ៖ ៥៣)

الثالثُ : عَنْ ابْنِ مَسْعُودٍ رضـي اللّهَّ عنه أَنَّ النَّبِيَّ صَلّى اللهُ عَلَيْهِ وسَلَّم كَانَ يَقُولُ : «اللَّهُمَّ إِنِّي أَسْأَلُكَ الْهُدَى وَالتُّقَى وَالْعفافَ والْغِنَى » رواه مسلم .

ទីបី: អំពី អ៊ីបនូម៉ាស្អូទ رضـي الله عنه ថា: ណាពី ﷺ ធ្លាប់បានសុំពីអល់ឡោះថា : ឱអល់ឡោះ!ប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវការចង្អុលបង្ហាញ ការគោរពកោត ខ្លាចទ្រង់ ការស្អាតស្អំ(ពីបាបកម្មផ្សេងៗ) និងការគ្រប់គ្រាន់ដែលមិនសុំពីអ្នក ដទៃ។ (រាយការណ៍ដោយមូស្លីម)

(Riyad as-Salihin 71)

~Sin មិនអាចកើតឡើងទេប្រសិនបើធ្វើដោយគ្មានចេតនា ដូចជាការហៅកូនចិញ្ចឹមមិនតាមត្រកូលរបស់ពួកគេ

(សំរាប់បាបកម្មធំ جُنَاَحَ និង خطاء)

(al-Quran 33:5)

~Sin មួយចំនួននឹងកើតមាននៅពេលណាការកាត់ក្តីមិនទៅតាមអ្វីដែលអល់ឡោះជាម្ចាស់បញ្ចុះមក ឬគម្ពីរ al-Quran ដូចនេះអល់ឡោះមានបំណងឱ្យពួកគេរងទារុណកម្មដោយសារបាបកម្មនោះ

Caption

(សំរាប់បាបកម្ម ذَنب)

(al-Quran 5:49)

~Sin សំរាប់ការកាត់ក្តីមិនទៅតាមអ្វីដែលអល់ឡោះជាម្ចាស់ បញ្ចុះមក ឬគម្ពីរ al-Quran

(សំរាប់បាបកម្ម ذَنب)

(al-Quran 5:49)

~អំពើល្អលុប បំបាត់អំពើអាក្រក់ ហើយនោះគឺជាការរំលឹកទូន្មានសម្រាប់បណ្ដាអ្នក ដែលមានសតិសម្បជញ្ញៈ

(សំរាប់បាបកម្ម السَّيِّئَاتِ)

(al-Quran 11:114)

~ការសង្ស័យមួយចំនួន គឺជាបាបកម្ម

(សំរាប់បាបកម្ម إِثْمٌ)

(al-Quran 49:12)

~ខ្ញុំទទួលស្គាល់នូវបាបកម្មរបស់ខ្ញុំ ហេតុនេះសូមអល់ឡោះអភ័យទោសអោយខ្ញុំផង ព្រោះគ្មានអ្នកណាម្នាក់អាចអភ័យទោសអោយខ្ញុំក្រៅពីទ្រង់ឡើយ

(សំរាប់បាបកម្ម ذَنْب)

(Riyad as-Salihin 1875)

~ខ្ញុំសុំពីអល់ឡោះជាម្ចាស់នូវការស្អាតស្អំអំពីបាបកម្មផ្សេងៗ

Caption

ការចង្អុលបង្ហាញ ការគោរពកោត ខ្លាចទ្រង់ និងការគ្រប់គ្រាន់ដែលមិនសុំពីអ្នក ដទៃ។

(Riyad as-Salihin 71)

~ចូរពួកអ្នកជួយគ្នាក្នុងការធ្វើអំពើល្អ និងកោតខ្លាចអល់ឡោះ។ ហើយចូរពួកអ្នកកុំជួយគ្នាក្នុងការធ្វើអំពើបាបកម្ម និងធ្វើជាសត្រូវនឹងគ្នាឱ្យសោះ

(សំរាប់បាបកម្ម إِثْمٌ)

(al-Quran 5:2)

~ចូរកុំពិភាក្សាគ្នានូវអ្វីដែលជាអំពើបាបកម្ម និងជាប្រការដែលនាំឱ្យក្លាយជាសត្រូវនឹងគ្នា ហើយនិងជាការប្រឆាំង ចំពោះអ្នកនាំសាររបស់អល់ឡោះជាម្ចាស់ឲ្យសោះ

បើពិភាក្សាគ្នាដោយស្ងាត់ៗត្រូវពិភាក្សាប្រការដែលល្អៗ និងជាប្រការដែលនាំឱ្យកោតខ្លាចអល់ឡោះ

(សំរាប់បាបកម្ម إِثْمَ)

(al-Quran 58:9)

~ចូរសុំខមាលទោសអំពីអល់ឡោះជាម្ចាស់ចំពោះបាបកម្មរបស់អ្នក និងត្រូវលើកតម្កើងដោយកោតសរសើរចំពោះម្ចាស់របស់អ្នកទាំងល្ងាចទាំងព្រឹកចុះ។

(សំរាប់បាបកម្ម ذَنْب)

(al-Quran 40:55)

~ចូរសុំខមាលទោសអំពីអល់ឡោះជាម្ចាស់ចំពោះបាបកម្មរបស់អ្នក និងបាបកម្មបណ្ដាអ្នកមានជំនឿប្រុស និងបណ្ដាអ្នកមានជំនឿស្រីចុះ

(សំរាប់បាបកម្ម ذَنْب)

(al-Quran 47:19)

Caption

~Habil មិនលើកដៃសម្លាប់ Qabil នោះទេដែលទុកឲ្យខ្លួនស្លាប់ដោយសារគាត់ខ្លាចអល់ឡោះជាម្ចាស់ ហើយចង់ឱ្យ

Qabil ពេលដែលស្លាប់ទៅនឹងនាំទៅជាមួយនូវបាបកម្ម ដោយសារការសម្លាប់ប្អូន និងបាបកម្មរបស់ខ្លួនឯង ដូចនេះ Qabil នឹងស្ថិតនៅក្នុងចំណោមពួកឋាននរក

(សំរាប់បាបកម្ម إِثْمَ)

(al-Quran 5:27-29)

~ភរិយារបស់អាហ្ស៊ីសដែលចង់ប្រលោមទៅលើអ្នកបម្រើរបស់ខ្លួនជាណាពីយូសុហ្វនោះគឺស្ថិតក្នុងចំណោមអ្នកដែល មានកំហុស

(សំរាប់បាបកម្ម ذَنْب)

(al-Quran 12:9)

~ប្រជាជនណាព្វី Nuh ដោយសារតែបាបកម្មទាំងឡាយរបស់ពួកគេពួកគេត្រូវ បានគេពន្លិចក្នុងទឹកជំនន់រួចត្រូវបានគេបញ្ចូលទៅក្នុងនរក។ ហើយពួកគេគ្មានអ្នកណាជួយក្រៅពីអល់ឡោះឡើយ

(សំរាប់បាបកម្ម خطيئة)

(al-Quran 24:25)

~Children of Israel បានបំពានកិច្ចសន្យាជាមួយអល់ឡោះដោយពួកគេជួយសត្រូវរបស់ខ្លួនប្រឆាំងនឹងគ្នាឯង ដោយប្រព្រឹត្តបាបកម្មនិងរំលោភបំពាន ការកាប់សម្លាប់គ្នាឯងបណ្តេញគ្នារបស់ពួកគេចេញពីលំនៅដ្ឋានជាដើម

(សំរាប់បាបកម្ម إِثْم)

(al-Quran 2:85)

~Children of Israel ដែលប្រើពាក្យថា Hitta (សូមលុបលាងបាបកម្មរបស់យើងផង) និងចូលតាមទ្វារ ដោយមានការឱនលំទោននោះ ដូចនេះអល់ឡោះនឹងអភ័យទោសបាបកម្មពួកគេ

Caption

(សំរាប់បាបកម្ម خَطَايَا)

(al-Quran 2:58, 7:161)
(Sahih Muslim 3015)

~ពួក Yahudi ចូលចិត្តពិភាក្សាគ្នាដោយស្ងាត់ៗនូវអ្វីដែលជាអំពើបាបកម្ម និងជាប្រការដែលនាំឱ្យក្លាយជាសត្រូវនឹងគ្នា ហើយនិងជាការប្រឆាំងនឹងអ្នកនាំសាររបស់អល់ឡោះជាម្ចាស់ទៀតផង

(សំរាប់បាបកម្ម إِثْم)

(al-Quran 58:8)

~ពួក Yahudi ភាគច្រើនរហ័សធ្វើបាបកម្ម បំពាន និងស៊ីទ្រព្យសម្បត្តិដែលគេហាមឃាត់ ហើយទាំងនេះគឺអាក្រក់បំផុត

(សំរាប់បាបកម្ម إِثْم)

(al-Quran 5:62)

~ពួកគ្រូមន្តអាគមនៃស្តេច Pharaoh បានសារភាពកំហុស ដោយបានជឿនឹងអល់ឡោះជាម្ចាស់ និងសំអាតខ្លួនរបស់ពួកគេអំពីបាបកម្ម ដើម្បីទ្រង់នឹងអភ័យទោសនូវកំហុសឆ្គងទាំងឡាយរបស់ពួកគេ

(សំរាប់បាបកម្ម خَطَايَا)

(al-Quran 20:73-76)

~ពួកគ្រូមន្តអាគមនៃស្តេច Pharaoh បាននិយាយថាម្ចាស់របស់ពួកយើង នឹងអភ័យទោសឱ្យពួកយើងនូវរាល់កំហុសឆ្គងរបស់យើងដោយសារ ពួកយើងជាអ្នកមានជំនឿមុនគេ។

(សំរាប់បាបកម្ម خَطَايَا)

Caption

(al-Quran 26:51)

~Satan ជាអ្នកប្រើឲ្យមនុស្សប្រព្រឹត្តអំពើអសីលធម៌និងប្រការ អាក្រក់ផ្សេងៗនៅពេលយើងដើរតាមពួកវា

(al-Quran 24:21)

~kāfir នៅថ្ងៃបរលោកបានទទួលស្គាល់នូវបាបកម្មៗរបស់ខ្លួន

(សំរាប់បាបកម្ម ذَنْب)

(al-Quran 67:11)

~kāfir អះអាងថាពួកគេនឹងទទួលខុសត្រូវនូវកំហុសឆ្គងទាំងឡាយរបស់អ្នក mu'min បើសិនពួកគេធ្វើតាមមាគ៌ារបស់ខ្លួន តែពួកគេមិនអាចទទួលខុសត្រូវអំពីកំហុសឆ្គងរបស់ខ្លួន ឯងផ្ទាល់បន្តិចណាទ្បើយ
(សំរាប់បាបកម្ម خَطَٰيَٰ)
(al-Quran 29:12)

~kāfir នឹងរែកពន់បាបកម្មទាំងឡាយរបស់ពួកគេ និងបាបកម្មផ្សេងទៀតជាមួយនឹងបាបកម្មរបស់ពួកគេ
(សំរាប់បាបកម្ម خَطَٰيَٰ)
(al-Quran 29:13)

~Allāh គឺជាម្ចាស់ដែលត្រូវគេសង្ឃឹមយ៉ាងច្បាស់ថានឹងអភ័យទោសនូវរាល់កំហុសឆ្គងនៅថ្ងៃជំនុំជំរះ
(សំរាប់បាបកម្ម خَطِيٓـَٔةَ)
Caption
(al-Quran 26:82)

~Allāh បានហាមឃាត់ប្រព្រឹត្តអំពើបាបកម្ម ការបំពានក្រៅពីការពិត ការប្រព្រឹត្តអំពើអាក្រក់ទាំងឡាយទោះបីជាលាតត្រដាង ឬលាក់បាំងពីវាក៏ដោយហើយនិងការស្ហឹរិកនឹងអល់ឡោះនូវអ្វីដែលទ្រង់មិនបានបញ្ចុះភស្តុតាងណាមួយចំពោះវា ព្រមទាំងពួកដែលនិយាយបំផ្លើសលើ អល់ឡោះនូវអ្វីដែលពួកអ្នកមិនដឹង
(សំរាប់បាបកម្ម إِثْمَ)
(al-Quran 7:33)

~Allāh នឹងជម្រះបាបកម្មជនណាដែលទ្រង់មានចេតនា ហើយប្រសិនបើគ្មានការប្រោសប្រទានរបស់អល់ឡោះនិងក្ដីមេត្តាករុណារបស់ទ្រង់ទេនោះ គ្មានអ្នកណាម្នាក់បានជ្រះស្អាតពីអំពើបាបកម្មនោះឡើយ

(al-Quran 24:21)

~Allāh ជាម្ចាស់អភ័យទោសនូវរាល់បាបកម្មទាំងឡាយនិងជាអ្នកទទួលការសារភាពកំហុស និងជាអ្នកដែលមានការ ប្រោសប្រទានបំផុត និងជាអ្នកដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរ

(សំរាប់បាបកម្ម ذَنب)

(al-Quran 40:3)

~Allāh បានផ្ដល់ក្ដីមេត្តាករុណាដល់ពួកគេសំរាប់ជនណានៅពេលដែលអល់ឡោះជាម្ចាស់បានថែរក្សាពួកគេអំពីប្រការអាក្រក់ទាំងឡាយនោះ

(សំរាប់បាបកម្ម السَّيِّئَاتِ)

(al-Quran 40:9)

Caption

~Allāh ជាម្ចាស់ដែលអភ័យទោសនូវរាល់កំហុសទាំងឡាយ ហើយគ្មានជនណាអភ័យទោសដូចនេះទេ

(សំរាប់បាបកម្ម ذَنب)

(al-Quran 3:135)

~Allāh ជាម្ចាស់នឹងអភ័យទោសចំពោះបាបកម្មដែលបានសាងកន្លងទៅ និងបាបកម្មដែលមិនទាន់បានសាងចំពោះណាពួី និងអ្នកមានជំនឿ

(សំរាប់បាបកម្ម ذَنب)

(al-Quran 48:2)

~Allāh ជាម្ចាស់ជាអ្នកបំផ្លាញពួកគេដោយសាបាបកម្ម និង ការបំពាន

(សំរាប់បាបកម្ម ذَنب)

(al-Quran 29:40, 91:14)

~Allāh ផ្លាស់ប្តូរវារវាងមនុស្សលោកម្តងទទួលជោគជ័យ ម្តងទទួលបរាជ័យ ដើម្បីសំអាតបាបកម្មអ្នកមានជំនឿ និងបំផ្លាញពួក kāfir និងដើម្បីដឹងថាអ្នកណាជាអ្នក mu’min និងដើម្បីឲ្យពួកគេធ្វើជាសាក្សីដល់អ្នកដទៃ

(al-Quran 3:139-143)

~Allāh មានបំណងឱ្យពួកគេរងទារុណកម្ម ដោយសារបាបកម្មមួយចំនួនរបស់ពួកគេនៅពេលដែលមិនកាត់ក្តីទៅតាមអ្វីដែលអល់ឡោះជាម្ចាស់បញ្ចុះមក ឬតាមគម្ពីរ al-Quran

(សំរាប់បាបកម្ម ذَنب)

(al-Quran 5:49)

~ជនដែលនៅពេលធ្វើអាក្រក់អ្វីមួយពួកគេនឹកឃើញអល់ឡោះជាម្ចាស់ ហើយបានសុំអភ័យទោសរាល់កំហុសទាំងនោះ ដូចនេះអល់ឡោះនឹងអភ័យទោសឲ្យ

(សំរាប់បាបកម្ម ذَنب)

(al-Quran 3:135)

~ជនដែលប្រព្រឹត្តបាបកម្មគ្មានអ្នកជួយទេ ហើយពួកគេគ្មានអ្នកការពារក្រៅពីអល់ឡោះឡើយ

(សំរាប់បាបកម្ម السَّيِّئَاتِ)

(al-Quran 10:27)

~ជនដែលប្រព្រឹត្តបាបកម្មនឹងគិតថា៖ អល់ឡោះជាម្ចាស់នឹង ចាត់ទុកពួកគេដូចបណ្តាអ្នកដែលមានជំនឿ និងបានសាង អំពើល្អត្រឹមត្រូវ គឺស្មើភាពគ្នាក្នុងការរស់នៅ និងការស្លាប់

(សំរាប់បាបកម្ម السَّيِّئَاتِ)

(al-Quran 45:21)

~Allāh ជាម្ចាស់ជាអ្នកបំផ្លាញពួកគេដោយសាបាបកម្ម និង ការបំពាន
(សំរាប់បាបកម្ម ذَنب)
(al-Quran 29:40, 91:14)

~Allāh ផ្លាស់ប្តូរវារវាងមនុស្សលោកម្តងទទួលជោគជ័យ ម្តងទទួលបរាជ័យ ដើម្បីសំអាតបាបកម្មអ្នកមានជំនឿ និងបំផ្លាញពួក kāfir និងដើម្បីដឹងថាអ្នកណាជាអ្នក mu'min និងដើម្បីឲ្យពួកគេធ្វើជាសាក្សីដល់អ្នកដទៃ
(al-Quran 3:139-143)

~Allāh មានបំណងឱ្យពួកគេរងទារុណកម្ម ដោយសារបាបកម្មមួយចំនួនរបស់ពួកគេនៅពេលដែលមិនកាត់ក្តីទៅតាមអ្វីដែលអល់ឡោះជាម្ចាស់បញ្ចុះមក ឬតាមគម្ពីរ al-Quran
(សំរាប់បាបកម្ម ذَنب)
(al-Quran 5:49)

~ជនដែលនៅពេលធ្វើអាក្រក់អ្វីមួយពួកគេនឹកឃើញអល់ឡោះជាម្ចាស់ ហើយបានសុំអភ័យទោសរាល់កំហុសទាំងនោះ ដូចនេះអល់ឡោះនឹងអភ័យទោសឲ្យ
(សំរាប់បាបកម្ម ذَنب)
(al-Quran 3:135)

~ជនដែលប្រព្រឹត្តបាបកម្មគ្មានអ្នកជួយទេ ហើយពួកគេគ្មានអ្នកការពារក្រៅពីអល់ឡោះឡើយ
(សំរាប់បាបកម្ម السَّيِّئَاتِ)
(al-Quran 10:27)

~ជនដែលប្រព្រឹត្តបាបកម្មនឹងគិតថា៖ អល់ឡោះជាម្ចាស់នឹង ចាត់ទុកពួកគេដូចបណ្តាអ្នកដែលមានជំនឿ និងបានសាង អំពើល្អត្រឹមត្រូវ គឺស្មើភាពគ្នាក្នុងការរស់នៅ និងការស្លាប់
(សំរាប់បាបកម្ម السَّيِّئَاتِ)
(al-Quran 45:21)

~ជនដែលធ្វើអំពើអាក្រក់ដោយភាពល្ងង់ខ្លៅ បន្ទាប់មកពួកគេសារភាពកំហុសភ្លាមៗ ពួកទាំងនោះត្រូវបាន អល់ឡោះទទួលយកការសារភាពកំហុសរបស់ពួកគេ

(al-Quran 4:17)

~ជនដែលសាងបាបកម្ម ឬប្រព្រឹត្តខុសបន្ទាប់មកគេទម្លាក់កំហុសនោះទៅលើអ្នកដែលគ្មានកំហុស ដូចនេះពួកគេនឹងទទួលរងនូវការមួលបង្កាច់ និងបាបកម្មនោះវិញយ៉ាងពិតប្រាកដ

(សំរាប់បាបកម្ម إِثْمَ និង خَطِيئَةً)

(al-Quran 4:112)

~ជនដែលសាងបាបកម្ម គឺពិតជាបានសាងបាបកម្មទៅលើ ខ្លួនឯង ដូចនេះជននោះនឹងទទួលបានអំពើដូច្នោះដែរ

(សំរាប់បាបកម្ម إِثْمَ)

(al-Quran 4:111, 6:120)

~ជនដែលចៀសពីអំពើបាបធំៗ និងទង្វើអាក្រក់ផ្សេងៗ គឺជាជនដែលនៅពេលពួកគេខឹងសម្បាចំពោះជនណាម្នាក់ ពួក គេតែងតែអភ័យទោសដល់ជននោះ។

(សំរាប់បាបកម្ម إِثْمَ)

(al-Quran 42:37)

~ជនដែលប្រព្រឹត្តបាបកម្ម ឬពួកដែលបានរៀបចំផែនការអាក្រក់នានានឹងត្រូវអល់ឡោះជាម្ចាស់បញ្ចុះទណ្ឌកម្មដូចជា៖

1.ដីលេប

2.ការដាក់ទារុណកម្មមកដល់ពួកគេខណៈដែលពួកគេមិនដឹងខ្លួន

3.ការដាក់ទណ្ឌកម្មពួកគេក្នុងពេលធ្វើដំណើរចុះឡើង ឬ នៅពេលរកស៊ីរបស់ពួកគេ

4.ការដាក់ទណ្ឌកម្មពួកគេក្នុងពេលដែលពួកគេភ័យរន្ធត់ ដោយសារការបាត់បង់ទ្រព្យសម្បត្តិនិងសុខភាព

(សំរាប់បាបកម្ម السَّيِّئَاتِ)
(al-Quran 16:45-47)

~គ្មានការអភ័យទោស Sin នោះទេជនដែលប្រព្រឹត្តអំពើអាក្រក់ និងជនដែលស្លាប់ក្នុងសភាពជាអ្នក kafir គឺមិនត្រូវគេទទួលការសារភាពកំហុសរបស់ពួកគេទេ ដោយសាពួកគេប្រព្រឹត្តអាក្រក់នៅពេលដែលសេចក្តីស្លាប់ចូលមកដល់ទើបនិយាយថាខ្ញុំសូមសារភាពកំហុសហើយឥឡូវនេះ ឯពួក kafir វិញពួកគេស្លាប់មុនការសារភាពកំហុសរបស់ពួកគេ
(សំរាប់បាបកម្ម السَّيِّئَاتِ)
(al-Quran 4:18)

Caption
•ជនដែលត្រូវគេអភ័យទោសបាបកម្ម

وَسَارِعُوا إِلَىٰ مَغْفِرَةٍ مِنْ رَبِّكُمْ وَجَنَّةٍ عَرْضُهَا السَّمَاوَاتُ وَالْأَرْضُ أُعِدَّتْ لِلْمُتَّقِينَ
سورة آل عمران:133
ហើយចូរពួកអ្នកប្រញាប់ប្រញាល់ទៅរកការអភ័យ ទោសពីម្ចាស់របស់ពួកអ្នក និងទៅរកឋានសួគ៌ដែលផ្ទៃរបស់វាដូច ផ្ទៃមេឃជាច្រើនជាន់និងផែនដីដែលគេបានរៀបចំវាសម្រាប់បណ្តា អ្នកដែលកោតខ្លាច។

وَلَيْسَتِ التَّوْبَةُ لِلَّذِينَ يَعْمَلُونَ السَّيِّئَاتِ حَتَّىٰ إِذَا حَضَرَ أَحَدَهُمُ الْمَوْتُ قَالَ إِنِّي تُبْتُ الْآنَ وَلَا الَّذِينَ يَمُوتُونَ وَهُمْ كُفَّارٌ ۚ أُولَٰئِكَ أَعْتَدْنَا لَهُمْ عَذَابًا أَلِيمًا
سورة النساء:18

ផ្ទុយទៅវិញការទទួលសារភាពកំហុសនោះមិនមែន សម្រាប់ពួកដែលប្រព្រឹត្តអំពើអាក្រក់រហូតនៅពេលដែលសេចក្តី ស្លាប់ចូលមកដល់ទើបនិយាយថា ខ្ញុំសូមសារភាពកំហុសហើយ ឥឡូវនេះ ហើយក៏មិនសម្រាប់ពួកដែលស្លាប់ក្នុងសភាពជាអ្នក ប្រឆាំងដែរ។ ពួកទាំងនោះគឺយើងបានត្រៀមសម្រាប់ពួកគេនូវ ទារុណកម្មដ៏សែនឈឺចាប់។

وَقِهِمُ السَّيِّئَاتِ ۚ وَمَن تَقِ السَّيِّئَاتِ يَوْمَئِذٍ فَقَدْ رَحِمْتَهُ ۚ وَذَٰلِكَ هُوَ الْفَوْزُ الْعَظِيمُ
سورة غافر:9

ហើយសូមទ្រង់មេត្តាថែរក្សាពួកគេអំពីប្រការអាក្រក់ទាំង ឡាយផង។ ហើយអ្នកណាដែលទ្រង់ថែរក្សាអំពីប្រការអាក្រក់ ទាំងឡាយនៅថ្ងៃនោះ(បរលោក) គឺទ្រង់ពិតជាបានផ្តល់ក្តីមេត្តា ករុណាដល់គេ។ ហើយនោះគឺជាជ័យជំនះដ៏ធំធេង។

1.ជនដែលអល់ឡោះជាម្ចាស់មានចេតនាអភ័យទោសឲ្យ

2.អ្នកមានជំនឿ mu'min

3.អ្នកដែលបរិច្ចាគទ្រព្យសម្បត្តិទាំងនៅពេល ធូរធារ និងពេលក្រខ្សត់

Caption

4.អ្នកដែលមានភាពអត់ធ្មត់ចំពោះកំហឹង

5.អ្នកដែលមានការអធ្យាស្រ័យដល់មនុស្សលោក

6.ពួកដែលនៅពេលដែលពួកគេធ្វើអំពើអាក្រក់អ្វីមួយ ឬពួកគេបំពានលើខ្លួនឯង គឺពួកគេនឹកឃើញអល់ឡោះ ហើយពួកគេសុំអភ័យទោសនូវរាល់ទោសកំហុសរបស់ពួកគេ

7.ពួកដែលមិនរឹងរូសចំពោះអ្វីដែលពួកគេបានប្រព្រឹត្តខណ: ដែលពួកគេដឹងហើយនោះ

8.អ្នកដែលបានអត់ធ្មត់ និងបានធ្វើអំពើល្អ

9.ពួកដែលអល់ឡោះជាម្ចាស់បានសាកល្បងរវាងពួកគេម្តងទទួលជោគជ័យ ម្តងទទួលបរាជ័យដើម្បីដឹងថាអ្នកណាជាអ្នក mu'min និង ដើម្បីឲ្យពួកគេធ្វើជាសាក្សីដល់អ្នកដទៃ

10.ពួកដែលប្រព្រឹត្តតែបាបកម្មតូច ហើយចៀសវាងអំពីបាបកម្មធំ និង Al-Fawahish (អំពើអសីលធម៌) ផ្សេងៗ

11.ពួកដែលសង្ឃឹមនូវការអាណិតស្រឡាញ់មកពីអល់ឡោះ ជាម្ចាស់ ដូចជាបណ្ដាអ្នកដែលមានជំនឿ និងបណ្ដាអ្នកដែល បានភៀសខ្លួន ព្រមទាំងបណ្ដាអ្នកដែលបានតស៊ូក្នុងមាគ៌ា របស់អល់ឡោះ

12.ពួកខ្ញុំបំរើរបស់អល់ឡោះជាម្ចាស់ធ្វើការសារភាពកំហុស ដោយមិនអស់សង្ឃឹមនឹងក្ដីមេត្តាករុណាពីអល់ឡោះជាម្ចាស់



13.ពួកអ្នកដែលបានអត់ធ្មត់ និងបានធ្វើតែអំពើល្អ

14.ពួកអ្នកសំអាតខ្លួនអំពីបាបកម្ម تَزَكَّى

15.ពួកអ្នកមានជំនឿនឹងអល់ឡោះជាម្ចាស់តែមិនមែនជាអ្នកអីស្លាមដើម្បីទ្រង់នឹងអភ័យទោសនូវកំហុសឆ្គងទាំងឡាយរបស់ពួកគេ ដូចជាពួកគ្រូមន្តអាគម

16.ពួកអះលីគីតាប (People of the Book) ដែលកោតខ្លាច និងមានជំនឿនឹងអល់ឡោះជាម្ចាស់

Caption

17.ពួកអ្នកអ៊ីស្លាមទាំងប្រុសទាំងស្រីដែលណាព្វីមូហាំម៉ាត់បានសុំខមាលទោសដល់ពួកគេ

18.ពួកអ្នកមិនធ្វើ Shirk សូម្បីតែមួយដង ដូចនេះអល់ឡោះជាម្ចាស់នឹងអភ័យទោសទោះបីជាបាបកម្មរបស់ពួកគេស្ទើរពាសពេញដីក៏ដោយ

19.ពួកអ្នកបួងសួងហើយបួងសួងទៀត ដោយមានក្ដីសង្ឃឹមចំពោះអល់ឡោះជាម្ចាស់ ដូចនេះអល់ឡោះជាម្ចាស់នឹងអភ័យទោសអោយ ហើយនឹងមិនខ្វល់អំពីបាបកម្មនោះឡើយ

20.ពួកអ្នកដែលកោតខ្លាចអល់ឡោះជាម្ចាស់ដោយអាថ៌កំបាំង ដូចនេះ នឹងទទួលបាននូវការអភ័យទោស និងផលបុណ្យដ៏ធំធេង

21.អ្នក Adhan

22.ពួកអ្នកសឡាតជួរទី 1

23.ពួកអ្នកសឡាត អ៊ីសានិងស៊ូពោះនៅម៉ាស្ជិត

24.ពួកអ្នកសឡាតជាមួយពួកយើង (អ្នកអីស្លាម)

25.ពួកដែលមិនមែនជា Mujahirin (អ្នកប្រកាសអំពីបាបកម្មរបស់ខ្លួន)

26.ពួកអ្នកដែលប្រព្រឹត្តអំពើអាក្រក់ឬបំពានលើ ខ្លួនឯងផ្ទាល់ក្រោយមកគេបានសុំអភ័យទោសពីអល់ឡោះ

27.ពួកអ្នកដែលប្រើពាក្យថា Hitta (សូមលុបលាងបាបកម្មរបស់យើងផង) និងចូលតាមទ្វារដោយមានការឱនលំទោន

28.ពួកអ្នកដែលអល់ឡោះជាម្ចាស់ថែរក្សាអំពីប្រការអាក្រក់

29.ពួកអ្នករំលឹកទៅចំពោះអល់ឡោះជាម្ចាស់ច្រើនៗ

ផ្សេងៗ...

Caption

•Sin ការលុបលាងរបស់វាមានដូចជា៖

1.ការសឡាតកាតព្វកិច្ច 5 ពេល

(សំរាប់បាបកម្ម السَّيِّئَاتِ)

(Riyad as-Salihin 434)

2.ការសឡាតជើរមាអះ (Congregation)

(សំរាប់បាបកម្ម أصاب (ʾaṣāba))

(Riyad as-Salihin 435)

3.ការអភ័យទោសរបស់អល់ឡោះជាម្ចាស់

(សំរាប់បាបកម្ម سَيِّئَةٍ)

(Riyad as-Salihin 413)

4.អ្នក mu’min នឹងត្រូវអល់ឡោះជាម្ចាស់អភ័យទោស និងផ្តល់បញ្ជីទង្វើល្អនៅថ្ងៃបរលោក

(សំរាប់បាបកម្ម ذَنب)

(Riyad as-Salihin 433)

5.អ្នក mu’min នឹងត្រូវអល់ឡោះជាម្ចាស់ផ្តល់ក្តីករុណា និងធ្វើអោយពួកគេទទួលស្គាល់នូវបាបកម្មរបស់ពួកគេនៅថ្ងៃបរលោក

(សំរាប់បាបកម្ម ذَنب)

(Riyad as-Salihin 433)

6.ការលោះជនមូស្លីមអំពីនរកតាមរយះយ៉ាហូទី ឬណាសរ៉នីម្នាក់ គឺយកបាបកម្មទាំងនោះទៅដាក់អោយយាហូទី ឬណាសរ៉នី

(សំរាប់បាបកម្ម ذَنب និងបាបកម្មច្រើន ឬមានទំហំប៉ុនភ្នំ)

(Riyad as-Salihin 432)

7.ការបួងសួងដោយមានក្តីសង្ឃឹមថានឹងមានការអភ័យទោស

(សំរាប់បាបកម្មទូទៅ)

Caption

(Riyad as-Salihin 442)

8.ការសុំខមាលទោសអំពីអល់ឡោះជាម្ចាស់ ទោះបីបុរសម្នាក់នោះបានប្រព្រឹត្តបាបកម្មពេញមេឃក៏ដោយ

(សំរាប់បាបកម្ម ذَنب)

(Riyad as-Salihin 442)

9.ការសុំខមាលទោសអំពីអល់ឡោះជាម្ចាស់ ទោះបីបុរសម្នាក់នោះបានប្រព្រឹត្តបាបកម្មស្ទើរពេញដីក៏ដោយ ហើយមិនត្រូវធ្វើ Shirk នឹងអល់ឡោះជាម្ចាស់នោះទេ

(សំរាប់បាបកម្ម خطايا)

(Riyad as-Salihin 442)

10.ការយកទឹក Wudu’ អោយបានល្អ ទោះបីមានការលំបាក ក៏ដោយ ហើយត្រូវដើរទៅសឡាតនៅម៉ាស្ជិតអោយបានច្រើន និងនៅរង់ចាំសឡាត

(សំរាប់បាបកម្ម خطايا)

(Riyad as-Salihin 131)
(Riyad as-Salihin 1030)
11.ការយកទឹក Wudu’ រាល់ទឹក ឬតំណក់ទឹកចុងក្រោយនឹងលុបលាងបាបកម្ម ហើយនឹងធ្វើឲ្យយើងស្អាតស្អំ

(សំរាប់បាបកម្ម خطايا)

(Riyad as-Salihin 129)
12.ការយកទឹក Wudu’ ឲ្យបានល្អត្រឹមត្រូវ បន្ទាប់មកទៅ សឡាតជុំអាត់(សឡាតថ្ងៃសុក្រ) ហើយនៅស្ងៀមដោយស្តាប់ខុត្ពហ្គះ (សុន្ទរកថាថ្ងៃជុំអាត់) ដូច្នេះនឹងត្រូវគេអភ័យទោសបាបកម្មរវាងថ្ងៃសុក្រនេះនិង ថ្ងៃសុក្របន្ទាប់ ព្រមទាំងបន្ថែមបីថ្ងៃថែមទៀត
(Riyad as-Salihin 128)
13.ការយកទឹក Wudu’ នៅថ្ងៃជុំអាត់ ការងូតទឹក លាបប្រេង ឬប្រើគ្រឿងក្រអូបពីផ្ទះរបស់គាត់ បន្ទាប់មកចេញទៅសឡាត ដោយមិនបានបំបែករវាងមនុស្សពីរនាក់ ហើយសឡាតនូវអ្វីដែលគេដាក់កាតព្វកិច្ចអោយ ព្រមទាំងបាននៅស្ងៀមនៅពេលដែលអ៊ីម៉ាំសូត្រឃុតហ្គះ ដូចនេះនឹងត្រូវគេអភ័យទោសអោយគាត់នៅចន្លោះជុំអាត់នោះ និងជុំអាត់មួយទៀត"
(Riyad as-Salihin 1154)
14.ការយកទឹក Wudu’ តាមរបៀបស៊ុណ្ណះរ៉ស៊ូលុលឡោះ ﷺ ដូចនេះនឹងត្រូវបានអភ័យទោសហើយនូវបាបកម្ម ដែលគាត់បានសាងកន្លង

(សំរាប់បាបកម្ម ذَنب)

(Riyad as-Salihin 1027)
15.ការយកទឹក Wudu’ ដោយល្អត្រឹមត្រូវនោះបាបកម្មនឹងចេញពីខ្លួនប្រាណសូម្បីតែនៅក្រោមក្រចក

(សំរាប់បាបកម្ម خطايا) (Riyad as-Salihin 1026)

16.ការសឡ្បាតឲ្យបានទៀងទាត់ជានិច្ច គឺការសឡ្បាតកាតព្វកិច្ច 5 ពេល ការសឡ្បាតពីថ្ងៃជុំអាត់ (ថ្ងៃសុក្រ)មួយទៅជុំអាត់ មួយទៀត និងពីខែរ៉ម៉ាឌនមួយទៅខែរ៉ម៉ាឌនមួយទៀត (នៅពេលជៀសវាងអំពីបាបកម្មធំ)

(Riyad as-Salihin 130)

17.ការជួយសត្វទាំងអស់ដែលមានជីវិត ដូចជានៅពេលពួកវាជិតស្លាប់ជាដើម ដែលធ្វើឲ្យអល់ឡោះជាម្ចាស់ថ្លៃង អំណរគុណ និងអភ័យទោសអោយ

(Riyad as-Salihin 126)

18.ការយកអ្វីមួយនៅតាមផ្លូវដែលបង្ករគ្រោះថ្នាក់ ដែលធ្វើឲ្យអល់ឡោះជាម្ចាស់ថ្លៃង អំណរគុណ និងអភ័យទោសអោយ

(Riyad as-Salihin 127)

19.ការសឡ្បាតកាតព្វកិច្ចដោយយកទឹក Wudu’ ឲ្យបានត្រឹមត្រូវ សឡ្បាតឲ្យបាននឹងនរ khusu’ និងឱនរូកុឲ្យបានត្រឹមត្រូវ ដូចនេះវានឹងជំរុះចោលនូវបាបកម្មកាលពីមុន (សំរាប់បាបកម្ម ذُنُوب ហើយមិនប្រព្រឹត្តនូវបាបកម្មធំ)

(Riyad as-Salihin 1046)

20.ការសឡ្បាតកាតព្វកិច្ច 5 ពេល វាគឺជាអំពើកុសលដែលអាចជំរុះបាបកម្មបាន

(សំរាប់បាបកម្ម السَّيِّئَاتِ)

(Riyad as-Salihin 1044)

21.អំពើកុសល ឬទង្វើល្អ វាជំរុះនូវបាបកម្មរបស់យើងបាន

(សំរាប់បាបកម្ម السَّيِّئَاتِ)

(Riyad as-Salihin 1044)
(Riyad as-Salihin 434)

22.ការសឡ្បាតកាតព្វកិច្ច 5 ពេល វាប្រៀបដូចទៅនឹង ការងូតទឹក 5 ពេលដែលអល់ឡោះជំរុះចោលនូវបាបកម្មទាំងឡាយ

(សំរាប់បាបកម្ម خطايا)

(Riyad as-Salihin 1042)

23.ការសុំខមាលទោស និងសារភាពកំហុស Taubat

(Sahih Muslim 2748 a)

24.ការសុំខមាលទោសចំពោះអល់ឡោះជាម្ចាស់រៀងរាល់ពេលដែលបានប្រព្រឹត្តបាបកម្ម ដោយសាបុរសនោះដឹងថាមានម្ចាស់ម្នាក់ជាអ្នកលើកលែងទោស និង ដាក់ទោសសំរាប់ពួកគេ ។

(សំរាប់បាបកម្ម ذَنب)

(Riyad as-Salihin 421)

25.ការសុំខមាលទោសចំពោះអល់ឡោះជាម្ចាស់របស់ក្រុមដែលអល់ឡោះជាម្ចាស់បានយកមកជំនួសក្រុមអ្នក mu’min ដោយសារពួកគេមិនចង់ប្រព្រឹត្តបាបកម្ម ដូចនេះអល់ឡោះមហាអភ័យទោស មហាអាណិតស្រឡាញ់ (សំរាប់បាបកម្ម ذَنب)

(Riyad as-Salihin 422)

26.ការសុំខមាលទោសចំពោះអល់ឡោះជាម្ចាស់របស់ក្រុមដែលអល់ឡោះជាម្ចាស់បានបង្កើតថ្មីដើម្បីឲ្យពួកគេសាងបាបកម្ម ដោយសារពួកអ្នក mu’min មិនចង់ប្រព្រឹត្តបាបកម្ម

(Riyad as-Salihin 423)

Caption

27.ការធ្វើបុណ្យ Hajj ដើម្បីអល់ឡោះជាម្ចាស់ ដោយមិន បានរួមភេទជាមួយប្រពន្ធ និង មិនប្រព្រឹត្តបាបកម្ម ឬអំពើ fasiq ហើយនឹងត្រឡប់មកវិញដោយគ្មានបាបកម្មដូចទារកទើបតែកើត

(សំរាប់បាបកម្ម ذَنب)

(Sahih al-Bukhari 1521)
(Jami` at-Tirmidhi 811)

28.ការ tawbah (ការទទួលកំហុសត្រឡប់ទៅរកព្រះវិញ) ទោះបីបាបកម្មដែលបានប្រព្រឹត្តច្រើនរហូតទៅដល់លើ មេឃក៏ដោយ

(សំរាប់បាបកម្ម خطايا)

(Sunan Ibn Majah 4248)

29.ការសំអាត ឬកប់ស្លេស ទឹកមាត់របស់ខ្លួនបន្ទាប់ពីស្តោះនៅក្នុង Masjid រួច

(សំរាប់បាបកម្ម خطايا)

(Sahih al-Bukhari 415)
30.ការបួសថ្ងៃ 'Ashura' សង្ឃឹមថាវានឹងអាចលុបលាងបាបកម្មឆ្នាំមុន

(Jami` at-Tirmidhi 752)
31.ការទទួលស្គាល់កំហុស ការឈប់ ការសុំខមាលទោស របស់អ្នក mu’min នោះចិត្ត

របស់គេនឹងស្អាតជាថ្មីអំពី ចំនុចខ្មៅ ឬ Ran

(សំរាប់បាបកម្ម ذَنب)

(Sunan Ibn Majah 4244)
(al-Quran 83:14)
32.អ្នក Mu’min រាល់ៗពួកគេនឹងត្រូវបានអល់ឡោះជាម្ចាស់ អភ័យទោសក៏ប៉ុន្តែ

លើកលែងតែអ្នក Mujahirin (ជាមនុស្សប្រព្រឹត្តបាបកម្មដោយបើកចំហរ និងប្រកាសនូវ

បាបកម្មរបស់ពួកគេចំពោះមនុស្សលោក)

(Sahih al-Bukhari 6069)
33.អ្នក Mu’min ឬជនមូស្លីមដែលបានជួបប្រទះនឹងជម្ងឺក្តៅ ខ្លួន ជួបគ្រោះថ្នាក់ផ្សេងៗ

Caption

សូម្បីបន្លារមុតជើង គឺវាជាការលុបលាងបាបកម្ម និងដើម្បីបង្កើនឋានៈរបស់ពួកគេ

(សំរាប់បាបកម្ម خطايا)

(Sahih Muslim 2572 b)
(Sahih al-Bukhari 5647)
(Al-Adab Al-Mufrad 497)
34.ការសឡាតស៊ុណ្ណះពេលយប់នៃខែ Ramadan ពោរពេញទៅដោយជំនឿ និង

សង្ឃឹមថានឹងទទួលបានផលបុណ្យអំពីអល់ឡោះជាម្ចាស់ ដូចនេះបាបកម្មពីមុនៗមកនឹង

ត្រូវបានអភ័យទោសឲ្យ

(សំរាប់បាបកម្ម ذَنب)

(Sunan an-Nasa'i 5027)

35.ការសឡាតពេញមួយយប់ Lailat Al-Qadr ពោរពេញទៅដោយជំនឿ និង សង្ឃឹមថានឹងទទួលបានផលបុណ្យអំពីអល់ឡោះជាម្ចាស់ ដូចនេះបាបកម្មពីមុនៗមកនឹងត្រូវបានអភ័យទោសឲ្យ

(សំរាប់បាបកម្ម ذَنب)

(Sunan an-Nasa'i 5027)

36.ការធ្វើ 'Umrah មួយទៅ 'Umrah មួយទៀត វានឹងលុបលាងបាបកម្មរវាងនោះ

(Jami` at-Tirmidhi 933)

37.ការធ្វើបុណ្យ Hajj និងការបន្តធ្វើ ’Umrah បន្ទាប់ពីនោះ វានឹងលុបលាងអំពើបាប និង ភាពក្រីក្រចេញដូចជាស្នប់ដកភាពមិនសុទ្ធចេញអំពីដែក

(សំរាប់បាបកម្ម ذَنب)

(Sunan an-Nasa'i 2630)

38.ការបួសខែ Ramadan ពោពេញទៅដោយជំនឿ និងមានក្តីសង្ឃឹមថានិងទទួលបានផលបុណ្យអំពីអល់ឡោះជាម្ចាស់នឹងត្រូវបានអភ័យទោសនូវបាបកម្មកន្លងមក

(សំរាប់បាបកម្ម ذَنب)

Caption

(Sunan an-Nasa'i 2205)

39.ការចាប់ដៃរលាក់នៅពេលអ្នកអីស្លាមជួបគ្នា ។ ការអភ័យទោសកើតឡើងកំឡុងពេលដែលពួកគេមុននឹងចាកចេញ

(Sunan Abi Dawud 5212)

40.ការចង់ទៅជួបអល់ឡោះជាម្ចាស់ ដូចនេះបើពួកគេមានបាបកម្មស្ទើរពេញដី ប៉ុន្តែគេមិនបានធ្វើស៊ិរិកអ្វីមួយនោះអល់ឡោះនឹងជួបគេដោយផ្តល់ការអភ័យទោសអោយពួកគេទាំងអស់

(សំរាប់បាបកម្ម خَطِيئَةً)

(Riyad as-Salihin 413)

41.ការលាដៃរបស់អល់ឡោះជាម្ចាស់ដើម្បីទទួលយកការសារភាពកំហុសអ្នកដែលបានប្រព្រឹត្តបាបកម្មរហូតដល់ថ្ងៃរះពីទិសខាងលិច ។ ដូចនេះព្រះបានលាដៃនៅពេលថ្ងៃសំរាប់ អ្នក مُسيء នៅពេលយប់ និងលាដៃនៅពេលយប់សំរាប់ អ្នក مُسيء នៅពេលថ្ងៃ

(សំរាប់អ្នក مُسيء)

(Riyad as-Salihin 437)

42.ការសារភាពកំហុសដោយមានក្តីសង្ឃឹមរបស់ខ្ញុំបំរើរបស់អល់ឡោះជាម្ចាស់ដែលបានបំពានលើខ្លួនឯង

(សំរាប់បាបកម្ម ذَنب)

(al-Quran 39:53)

43.ការអភ័យទោសរបស់អល់ឡោះជាម្ចាស់ មានដូចជាការអភ័យទោសចំពោះអ្នកបរិច្ចាគទោះនៅពេលក្រ ឬមាន អ្នកសុំខមាលទោស អ្នកអត់ធ្មត់ អ្នកដែលមានការអធ្យាស្រ័យ អ្នកមិនរឹងរូស...

(សំរាប់បាបកម្ម ذَنب)

(al-Quran 3:134-136)

Caption

44.ការបន្លឺសំលេង Aameen បន្ទាប់ពី Imam សូត្រ Aameen នៅក្នុងសឡាតបើស្របពេលតែមួយជាមួយ Malaikah សូត្រ Aameen ដែរនោះ ដូចនេះបាបកម្មពីមុនៗត្រូវបានអភ័យទោស

(សំរាប់បាបកម្ម ذَنب)

(Sahih Muslim 410 a)

45.ការបន្លឺសំលេង Aameen បន្ទាប់ពី Imam សូត្រ Aameen នៅក្នុងសឡាតបើស្របពេលតែមួយជាមួយ Malaikah នៅលើមេឃសូត្រ Aameen ដែរនោះ ដូចនេះបាបកម្មពីមុនៗត្រូវបាន អភ័យទោស

(សំរាប់បាបកម្ម ذَنب)

(Sahih Muslim 410 c)

46.ការបន្លឺសំលេង Aameen បន្ទាប់ពី Imam សូត្រ

Aameen នៅក្នុងសឡាតបើស្របពេលតែមួយជាមួយអ្នករស់នៅឋានសួគ៌សូត្រ Aameen ដែរនោះ ដូចនេះបាបកម្មពីមុនៗត្រូវបាន អភ័យទោស

(សំរាប់បាបកម្ម ذَنب)

(Sahih Muslim 410 f)

47.ការ Salawat ទៅលើរ៉ស៊ូលុលឡោះ ﷺ ។ Salawat 1 ដង ដូចនេះអល់ឡោះជាម្ចាស់នឹង Salawat ទៅលើជននោះ 10 វិញ ហើយលុបចេញអំពើបាបរបស់ពួកគេចំនួន 10 និងលើក 10 ឋានៈ

(សំរាប់បាបកម្ម خَطِيئَة)

(Sunan an-Nasa'i 1297)

48.ការសង្ឃឹមរបស់អ្នកអីស្លាមថានឹងបានផលបុណ្យអំពីគ្រោះថ្នាក់ដូចជាបន្លារចាក់ ដូចនេះអល់ឡោះជាម្ចាស់នឹងអភ័យទោសឲ្យពួកគេនៅថ្ងៃធ្វើឲ្យរស់ឡើងវិញ

(សំរាប់បាបកម្ម خَطَايَا)

(Al-Adab Al-Mufrad 507)

Caption

49.ការសុំអភ័យទោស និងមានជំនឿជឿចំពោះអល់ឡោះជាម្ចាស់វិញបន្ទាប់ពីប្រព្រឹត្តបាបកម្មហើយនោះ ដូចនេះអល់ឡោះនឹងអភ័យទោសសំរាប់ពួកគេ

(សំរាប់បាបកម្ម السَّيِّئَاتِ)

(al-Quran 7:153)

50.ការមិនរឹងរូសចំពោះអ្វីដែល ពួកគេបានប្រព្រឹត្តនោះទេ ខណៈដែលពួកគេដឹងហើយនោះ ដូចនេះអល់ឡោះជាម្ចាស់ នឹងអភ័យទោសសំរាប់ពួកគេ

(សំរាប់បាបកម្ម ذَنب)

(al-Quran 3:135)

51.ការសុំអភ័យទោសបន្ទាប់ពីប្រព្រឹត្តអំពើអាក្រក់ឬបំពានលើខ្លួនឯងរួច

(al-Quran 4:110)

52.ការកោតខ្លាច និងមានជំនឿនឹងអល់ឡោះជាម្ចាស់របស់ពួកអះលីគីតាប (People of the Book)
(សំរាប់បាបកម្ម السَّيِّئَاتِ)

(al-Quran 5:65)
53.ការមិនធ្វើ Shirk សូម្បីតែមួយដង ដូចនេះអល់ឡោះជាម្ចាស់នឹងអភ័យទោសទោះបីជាបាបកម្មរបស់ពួកគេស្ទើរពាសពេញដីក៏ដោយ

(សំរាប់បាបកម្ម خَطَايَا)

(Riyad as-Salihin 1878)
54.ការបួងសួងហើយបួងសួងទៀត ដោយមានក្តីសង្ឃឹមចំពោះអល់ឡោះជាម្ចាស់ ដូចនេះ អល់ឡោះជាម្ចាស់នឹងអភ័យទោសអោយ ហើយនឹងមិនខ្វល់អំពីបាបកម្មនោះឡើយ

(Riyad as-Salihin 1878)
55.ការប្រើពាក្យ Hitta (សូមលុបលាងបាបកម្មរបស់ពួកយើងផង) ដូចនេះអល់ឡោះជាម្ចាស់នឹងអភ័យទោសបាបកម្ម

(សំរាប់បាបកម្ម خَطَايَا)

(al-Quran 2:58)
(Sahih Muslim 3015)
56.ការកោតខ្លាចម្ចាស់របស់ពួកគេដោយអាថ៌កំបាំង ដូចនេះ នឹងទទួលបាននូវការអភ័យទោស និងផលបុណ្យដ៏ធំធេង។

(al-Quran 67:12)
57.ការសុំខមាលទោសរបស់ណាព្វីមូហាំម៉ាត់

(al-Quran 47:19)
58.ការទទួលរបស់អល់ឡោះជាម្ចាស់នៃការសារភាពកំហុសសម្រាប់ពួកដែលធ្វើអំពើអាក្រក់ដោយភាពល្ងង់ខ្លៅដោយពួកគេសារភាពកំហុសភ្លាមៗ

(al-Quran 4:17)
59.ការ Adhan ការសឡាតជូរទី 1 ការសឡាត អ៊ីសានិងស៊ូពោះនៅម៉ាស្ជិត

(Riyad as-Salihin 1033)

60.ក្ដីអាណិតស្រឡាញ់ (رحمة) អំពីអល់ឡោះជាម្ចាស់ ។ នៅថ្ងៃបរលោកអល់ឡោះជាម្ចាស់នឹងបំពេញក្ដីករុណារបស់ទ្រង់

(al-Quran 2:218, 39:53)

61.ការសូត្រ និង Zikr មួយចំនួនដូចខាងក្រោមនេះ៖

a.ការសូត្របន្ទាប់ពីបានលឺអាត្សាន Adhan រួចថា:

" أَشْهَدُ أَنْ لا إِلَه إِلا اللهُ وَحْدَهُ لا شَرِيكَ لَهُ ، وَأَنَّ مُحَمَّداً عَبْدُهُ وَرَسُولُهُ ، رَضِيتُ بِاللهِ رَبّاً ، وَبِمُحَمَّدٍ رَسُولاً ، وَبِالإِسْلامِ دِيناً "

(ខ្ញុំធ្វើសាក្សីថា គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ត្រឹមត្រូវ មានតែ អល់ឡោះម្នាក់គត់ គ្មានទេស៊ីរិកចំពោះទ្រង់ ហើយមូហាំម៉ាត់គឺជាខ្ញុំ និងជារ៉សូល (អ្នកនាំសារ)របស់ទ្រង់។ ខ្ញុំពេញចិត្តនឹងយកអល់ឡោះធ្វើជាម្ចាស់ មូហាំម៉ាត់ ជារ៉សូល និងអ៊ីស្លាមធ្វើជាសាសនា) ។

»នឹងត្រូវគេអភ័យទោសអោយនូវបាបកម្ម

Caption

(សំរាប់បាបកម្ម ذَنب)

(Riyad as-Salihin 1040)

b.ការសូត្រមួយថ្ងៃ 100 ដងនៃឃ្លាខាងក្រោមនេះនឹងលុបលាងបាបកម្មរបស់ពួកគេទោះបីមានច្រើនដូចពពុះសមុទ្រក៏ដោយ

سُبْحَانَ اللَّهِ وَبِحَمْدِهِ

(សំរាប់បាបកម្ម خَطَايَا)

(Mishkat al-Masabih 2296)

c.ការសូត្រខាងក្រោមនេះនឹងលុបលាងបាបកម្មរបស់ពួកគេទោះបីជាបានរត់ចោលជួរនៅក្នុងសមរភូមិក៏ដោយ

" أَسْتَغْفِرُ اللهَ الَّذِي لا إِلَهَ إِلا هُوَ الحَيُّ القَيُّومُ وَأَتُوبُ إِلَيهِ "
"ខ្ញុំសុំអភ័យទោសពីអល់ឡោះ ដែលគ្មានម្ចាស់ណាដែលត្រូវគេគោរពសក្ការៈ ដ៏ត្រឹមត្រូវក្រៅពីទ្រង់ឡើយ ទ្រង់ជាអ្នករស់ជាអមតៈ និងមិនត្រូវការពឹងពាក់ អ្នកណាឡើយ ខ្ញុំសុំសារភាពកំហុសទៅចំពោះទ្រង់ "

(សំរាប់បាបកម្ម ذَنب)

(Riyad as-Salihin 1874)

d.ការសូត្រនៅពេលទទួលទានអាហាររួចថា៖

" الحَمْدُ للهِ الَّذِي أَطْعَمَنِي هَذَا الطعام ، وَرَزَقَنِيهِ مِنْ غَيْرِ حَوْلٍ مِنِّي وَلا قُوَّةٍ "
(ពាល់ការសរសើរទាំងឡាយ គឺសំរាប់អល់ឡោះដែលបានអោយខ្ញុំបានទទួលទាន អាហារនេះ និងបានផ្តល់លាភសក្ការៈនេះដល់ខ្ញុំ ដោយវាមិនមែនដោយសារការខំ ប្រឹងប្រែង ឬអានុភាពរបស់ខ្ញុំឡើយ)

»គេនឹងអភ័យទោសអោយគាត់នូវ បាបកម្មទាំងឡាយដែលគាត់បានសាងពីមុនមក

(សំរាប់បាបកម្ម ذَنب)

(Riyad as-Salihin 735)

e.ការសូត្រក្រោយពេលសឡាត៖

سُبْحَانَ اللهِ
(អល់ឡោះដ៏មហាបរិសុទ្ធ) ចំនួន៣៣ដង

الحَمْدُ لله
(ពាល់ការសរសើរទាំងឡាយគឺសំរាប់ អល់ឡោះ) ចំនួនពាពាដង
الله أكْبَرُ
(អល់ឡោះធំធេងបំផុត)ចំនួនពាពាដង និងសូត្រ បង្គ្រប់១០០ថា :
"لا إلهَ إلا اللهُ وَحْدَهُ لا شَرِيكَ لَهُ ، لَهُ المُلْكُ وَلَهُ الحَمْدُ ، وَهُوَ عَلى كُلِّ شَيْءٍ قَدِيرٌ"
(គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ត្រឹមត្រូវ មានតែអល់ឡោះម្នាក់គត់ គ្មានទេស៊ីរិកទៅចំពោះទ្រង់ ទ្រង់ជាម្ចាស់កម្មសិទ្ធិ ជាអ្នកត្រូវគេសរសើរ ហើយ ទ្រង់គឺជាអ្នកមានអានុភាពលើអ្វីៗទាំងអស់)



»គេនឹងអភ័យទោសអោយគាត់ ទោះជាបាបកម្មរបស់ គាត់ច្រើនដូចពពុះទឹកសមុទ្រក៏ដោយ
(សំរាប់បាបកម្ម خطَايا)
(Riyad as-Salihin 1419)

ផ្សេងៗ...

Caption